# សេចក្តីប្រកាសព័ត៌មានរួម

## សង្គមស៊ីវិលសំដែងការព្រួយបារម្ភចំពោះការវិវត្តន៍ថ្មីៗជុំវិញអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា និងទទូចសុំឱ្យសហគមន៍អន្តរជាតិសំដែងទស្សនៈជាចំហរ

*ភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១*

យើងទាំងអស់គ្នា ជាសមាជិកនៃអង្គការសង្គមស៊ីវិលកម្ពុជា សូមសំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការវិវត្តន៍ថ្មីៗរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ពាក់ព័ន្ធនឹងដំណើរការស៊ើបអង្កេត និងការចោទប្រកាន់លើសំណុំរឿង០០៣ និង០០៤។ យើងទាំងអស់គ្នាមានការព្រួយបារម្ភចំពោះអាណត្តិការងាររបស់ អ.វ.ត.ក ដែលត្រូវនាំខ្លួនមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មកើតឡើងនៅក្នុងរបបខ្មែរក្រហម ស្ថិតនៅលើហានិភ័យមួយក្នុងការបំពេញអាណត្តិនេះឱ្យបានចប់ចុងចប់ដើម។

យើងទាំងអស់គ្នា សូមទទូចសុំដល់អ្នកពាក់ព័ន្ធទាំងអស់ រួមមានៈ ជនរងគ្រោះ, ម្ចាស់ជំនួយ, រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ មេត្តាធ្វើយ៉ាងណា ដើម្បីធានាថា យុត្តិធម៌ត្រូវបានផ្តល់ឱ្យ ហើយយុត្តិធម៌ ត្រូវបានគេមើលឃើញថា កំពុងត្រូវបានបំពេញដោយ អ.វ.ត.ក ផងដែរ។

យើងទាំងអស់គ្នាក៏ទទូចសុំឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួម ដើម្បីធានាថា គោលបំណងរបស់ អ.វ.ត.ក ត្រូវបានបំពេញ ហើយកេរ្តិ៍ដំណែលរួមរបស់ អ.វ.ត.ក នឹងត្រូវប្រើប្រាស់ជាគំរូសំរាប់ការកែទំរង់ និងការអភិវឌ្ឍន៍នីតិរដ្ឋនៅប្រទេសកម្ពុជា។

ចៅក្រមទាំងអស់ ទោះបីជាចៅក្រមជាតិក្តី ឬចៅក្រមអន្តរជាតិក្តី តំរូវឱ្យជាបុគ្គលដែលមានចរិតលក្ខណៈល្អខ្ពង់ខ្ពស់ មិនលំអៀង មានសុចរិតភាព និងឯករាជ្យពេញលេញក្នុងការបំពេញមុខងាររបស់ខ្លួន។ ចៅក្រមទាំងអស់ត្រូវបានហាមទទួលយក ឬស្វែងរកការណែនាំណាមួយពីរដ្ឋាភិបាល ឬពីប្រភពណាមួយ។ ចំពោះសហព្រះរាជអាជ្ញារបស់ អ.វ.ត.ក ក៏ត្រូវតែគោរពទៅតាមលក្ខខណ្ឌ ស្តង់ដារដូចគ្នាអញ្ចឹងដែរ។ ភាពរីកចំរើនថ្មីៗជុំវិញសំណុំរឿង០០៣ និង០០៤ បានធ្វើឱ្យយើងមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីបញ្ហាអព្យាក្រឹត្យភាព, សេចក្តីសុចរិត និងឯករាជ្យភាពរបស់ចៅក្រម ដែលកំពុងតែរងនូវភាពមន្ទិលសង្ស័យ។

ប្រជាពលរដ្ឋកម្ពុជាទាំងអស់មាន *សិទ្ធិដឹង* នូវអ្វីដែលបានកើតឡើងក្រោមការដឹកនាំរបស់មេដឹកនាំខ្មែរក្រហម។ *សិទ្ធិដឹង* នេះ តំរូវឱ្យមានការទទួលបានការពិតចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម។ នៅក្នុងចំណោមមុខងារទាំងអស់របស់ខ្លួន មុខងារសំខាន់មួយ ដែល អ.វ.ត.ក កំពុងតែបំពេញ គឺការបង្កើតឱ្យបាននូវកំណត់ត្រាប្រវត្តិសាស្ត្រមួយអំពីអ្វីដែលបានកើតឡើងទាំងអស់នោះ។ វាច្បាស់ណាស់ដែលថា កំណត់ត្រាបែបនោះ ត្រូវតែមានលក្ខណៈជាក់លាក់ និងពេញលេញគ្រប់គ្រាន់ តាមដែលអាចធ្វើទៅបាន។ អ.វ.ត.ក ត្រូវតែធានាថា ខ្លួននឹងបង្កើតឱ្យមានកំណត់ត្រាមួយដែលគ្មានលក្ខណៈអវិជ្ជមាន ឬកែតំរូវចំពោះអ្វីដែលបានកើតឡើង។

ប្រជាពលរដ្ឋកម្ពុជាក៏មាន *សិទ្ធិទទួលបាននូវយុត្តិធម៌* ផងដែរ។ សិទ្ធិនេះ រួមមានសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមទៅក្នុងដំណើរការនៃប្រព័ន្ធយុត្តិធម៌ដោយពេញលេញប្រកបដោយអត្ថន័យ នៅគ្រប់តំណាក់កាលនៃនីតិវិធីទាំងអស់។ ដើម្បីឱ្យគេអនុវត្តនូវសិទ្ធិនេះប្រកបដោយប្រសិទ្ធភាពបាន ប្រជាពលរដ្ឋកម្ពុជាទាំងអស់ត្រូវការជាចាំបាច់នូវព័ត៌មានសាធារណៈដែលមានទាំងអស់។ ការផ្តល់ព័ត៌មានឱ្យបានច្រើន និងទូលំទូលាយដល់ជនរងគ្រោះទាំងឡាយ ក៏ត្រូវតែថ្លឹងថ្លែងជាមួយនឹងការការពារសិទ្ធិរបស់បុគ្គល ដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងរបបខ្មែរក្រហមផងដែរ ដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិឱ្យបានជាអតិបរមាបំផុត។ តាមរយៈសេចក្តីប្រកាសព័ត៌មានដែលចេញផ្សាយកាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ លោក អាន់ឌ្រូ ខេលី (Andrew Cayley) ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិ បានផ្តល់នូវព័ត៌មានអំពីអង្គហេតុមូលដ្ឋានខ្លះៗនៃសំណុំរឿង០០៣ ប៉ុណ្ណោះ។ ទោះបីជាយ៉ាងណាក៏ដោយ ព័ត៌មានប៉ុណ្ណឹងមិនទាន់គ្រប់គ្រាន់ និងចំពេលសំរាប់ឱ្យសង្គមស៊ីវិលបំពេញមុខងាររបស់ខ្លួន ក្នុងការជួយសំរបសំរួលឱ្យមានការចូលរួមរបស់ជនរងគ្រោះប្រកបដោយអត្ថន័យនៅឡើយទេ។ ក្នុងន័យនេះ អង្គការសង្គមស៊ីវិលកម្ពុជា សំណូមពរឱ្យផ្តល់កាន់តែឆាប់រហ័សនូវព័ត៌មាន និងពេញវេលាបន្ថែមទៀត ដើម្បីឱ្យគេអាចចូលរួមចំណែកការពារ និងតំណាងផលប្រយោជន៍របស់ជនរងគ្រោះកម្ពុជា នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ប្រកបដោយប្រសិទ្ធភាព។

យើងទាំងអស់គ្នាដែលបានគាំទ្រសេចក្តីថ្លែងការណ៍នេះនៅតែសង្ឃឹមថា ការសន្យារបស់ អ.វ.ត.ក ក្នុងការបង្កើត និងរក្សាឱ្យបាននូវស្តង់ដារមួយសំរាប់ធ្វើប្រសើរឡើងនូវនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជា។ នីតិរដ្ឋ, លទ្ធិប្រជាធិបតេយ្យ គោលការណ៍បែងចែកអំណាច ព្រមទាំងឯករាជ្យភាព និងភាពមិនលំអៀងរបស់ចៅក្រម គឺជាបញ្ហាដែលមានភាពពាក់ព័ន្ធគ្នា។ ដូចនេះ សំរាប់ប្រជាពលរដ្ឋកម្ពុជា វាជាការចាំបាច់ណាស់ដែលថា អ.វ.ត.ក ដែលជាតុលាការកូនកាត់បង្កើតនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា និងអនុវត្តច្បាប់ជាតិ និងច្បាប់អន្តរជាតិ នឹងត្រូវធ្វើតុលាការគំរូយ៉ាងពិតប្រាកដ សំរាប់ពេលអនាគត។

យើងសូមអំពាវនាវដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ទោះជាបុគ្គលម្នាក់ៗក្តី និងជាក្រុមក្តី ឱ្យចាត់វិធានការសមរម្យចាំបាច់នានា ដើម្បីធានាថា ការស៊ើបអង្កេតសំណុំរឿង០០៣ និង០០៤ បានពេញលេញពិតប្រាកដ, កំណត់ត្រាប្រវត្តិសាស្ត្រនៃរឿងរ៉ាវខ្មែរក្រហម ត្រូវបានបង្កើតឡើងដោយ អ.វ.ត.ក, ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិទទួលបាននូវយុត្តិធម៌ និងដឹងអំពីការពិតនៃសោកនាដកម្មក្នុងរបបខ្មែរក្រហម ហើយ សិទ្ធិក្នុងការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធីរបស់តុលាការ ត្រូវបានធានាពេញលេញ។

**ឈ្មោះ អង្គការ/សមាគម ដែលបានគាំទ្រសេចក្តីប្រកាសព័ត៌មានរួមនេះ**

១- សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

២- ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP)

៣- វិទ្យាស្ថានខ្មែរសំរាប់លទ្ធិប្រជាធិបតេយ្យ (KID)

៤- សមាគមយុវជនខ្មែរ (KYA)

៥- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)

៦- ជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC)

៧- អង្គការខារ៉ាមកម្ពុជា (CARAM Cambodia)

៨- មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR)

៩- សម្ព័ន្ធសិទ្ធិមនុស្ស និង សុខភាពកម្ពុជា (CHHRA)

១០- សមាគមសិទ្ធិមនុស្សចាំ-ខ្មែរឥស្លាមជនជាតិភាគតិច និង អភិវឌ្ឍន៍ (CKIMHRDA)

១១- បេសកកម្មសម្ព័ន្ធសប្បុរសធម៌ខ្មែរ (Generous)

១២- អង្គការការពារសិទ្ធិមនុស្សដើម្បីតម្លាភាព និងសន្តិភាព (HROTP)

១៣- សមាគមឥន្ទ្រទេវី (IDA)

១៤- វិទ្យាស្ថានខ្មែរដើម្បីអភិវឌ្ឍន៍ជាតិ (KIND)

១៥- សមាគមខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស (KKKHRA)

១៦- សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (KKKHRDA)

១៧- មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP)

១៨- អង្គការការពារយុត្តិធម៌កុមារ (PJJ)

១៩- អង្គការរក្សាការពារសិទ្ធិមនុស្ស នៃកម្ពុជា (VIGILANCE)

២០- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD)

២១- មជ្ឈមណ្ឌលដើម្បីយុត្តិធម៌ និងការបង្រួបបង្រួម (CJR)

២២- អង្គការកសាងសំលេងសហគមន៍ (BCV)

២៣- សមាគមនិស្សិតខ្មែរ (KSA)

២៤- គំរោងយុត្តិធម៌កម្ពុជា (CJI)

២៥- មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

២៦- អង្គការយុវសន្តិភាព (YFP)

២៧- កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)

២៨- មជ្ឈមណ្ឌលអន្តរជាតិដើម្បីការផ្សះផ្សារ-កម្ពុជា (ICfC)

២៩- សមាគមវិចិត្រសិល្បៈ (FAA)

៣០- លេខាធិការដ្ឋានគណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

៣១- គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ (COMFREL)

៣២- គណៈកម្មាធិការនិកហ្វិច (NICFEC)